## ១៨ សញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «បឋមវិជ្ជាជីវៈនគរបាល»

### ក- រូបសញ្ញា

### ខ- សញ្ញាសម្គាល់សម្រាប់សិក្ខាកាមជ័យលាភីនៃវគ្គ «បឋមវិជ្ជាជីវៈនគរបាល»

មានទម្រង់និងអត្ថន័យដូចខាងក្រោម៖

**ខ.១- ទម្រង់**

- មានរាងជារង្វង់មូល ដែលផ្នែកខាងលើក្នុងរង្វង់ មានផ្ទៃពណ៌ក្រហម ដោយសរសេរឈ្មោះក្រសួង រាងកោង «**ក្រសួងមហាផ្ទៃ**» ពណ៌មាស។
- ផ្នែកខាងក្នុងរង្វង់ មានឆ្នូតបីពណ៌មាសកាត់ទទឹងនិងឆ្នូតបីបណ្តោយរង្វង់ នៅចំណុចពាក់កណ្តាល នៃរង្វង់ទាំងសងខាង។ រីឯនៅខាងក្នុងផ្នែកខាងលើ មានសរសេរឈ្មោះក្រសួងរាងកោងជាភាសាអង់គ្លេស **“MINISTRY OF**
- **INTERIOR”**

- នៅចំកណ្តាល មានរូបព្រះគណេសពាក់កណ្តាលខ្លួន ពណ៌មាស ឯផ្ទៃខាងក្រោយពណ៌លឿងខ្ចី ហើយខាងក្រោម មានផ្កាចន្ទន៍ចំនួន៧ ដែលតំណាងឱ្យសាលានគរបាលជាតិទាំង៧ នៅតាមបណ្តា ខេត្តនៃប្រទេសកម្ពុជា។
- នៅខាងក្រោមផ្កាចន្ទន៍ មានសរសេរឈ្មោះបណ្ឌិត្យសភារាងកោងជាភាសាអង់គ្លេស **"POLICE ACADEMY OF CAMBODIA"**
- រីឯនៅខាងក្នុងផ្នែកខាងក្រោម មានបូក្រហម មានសរសេរឈ្មោះបណ្ឌិត្យសភាជាភាសាខ្មែររាងកោង **«បណ្ឌិត្យសភានគរបាលកម្ពុជា»** ពណ៌ស។
- ផ្នែកខាងក្រោមក្នុងរង្វង់ មានផ្ទៃពណ៌ផ្ទៃមេឃនិងកងចក្រ ដោយសរសេរឈ្មោះវគ្គរាងកោង **«បឋមវិជ្ជាជីវៈនគរបាល»** ពណ៌មាស។

### ខ.២- អត្ថន័យ

- **រង្វង់មូល មានរឹមពន្ធជុំវិញពណ៌មាស** តំណាងឱ្យភាពរឹងមាំ អត់ធ្មត់របស់មន្ត្រីនគរបាល ក្នុងការចូលរួមថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គមជូនប្រជាពលរដ្ឋទូទៅ។
- **ព្រះគណេស** ជាអាទិទេពតំណាងឱ្យច្បាប់ បញ្ញា ចំណេះដឹង និងជាអាទិទេពនៃការបំផ្លាញឧបសគ្គ និងអំពើអាក្រក់ទាំងឡាយ។ ក្នុងន័យនេះ ព្រះគណោសតំណាងឱ្យភាពជាអ្នកប្រាជ្ញ ជាបណ្ឌិត ជាអ្នកចេះដឹង អ្នកជួយដល់សត្វទាំងឡាយគ្រប់ទីកន្លែង ដោយប្រកាន់ខ្ជាប់នូវអំពើល្អ សុចរិតភាព ភាពម៉ឺងម៉ាត់ និងហ្មត់ចត់ព្រមទាំងបង្កើតឱ្យមានភាពសម្បូររុងរឿង វឌ្ឍនភាព និងវិបុលភាព។
- **បូមានពណ៌ផ្ទៃមេឃ** រំលេចវគ្គសិក្សា **«បឋមវិជ្ជាជីវៈនគរបាល»** ពណ៌មាសនិងកងចក្រ តំណាងឱ្យភាពម៉ត់ចត់ ម៉ឺងម៉ាត់ របស់មន្ត្រីនគរបាលក្នុងការប្រតិបត្តិការងារនៅគ្រប់ពេលវេលា។
- **បូមានពណ៌ក្រហម** តំណាងឱ្យភាពអង់អាចនិងកម្លាំងអនុភាពរបស់បណ្ឌិត្យសភានគរបាលកម្ពុជា ក្នុងការជំរុញឱ្យអង្គភាពចំណុះនិងអ្នកសិក្សាបំពេញបានតាមស្តង់ដាគុណភាព ដែលបានកំណត់។